សលាកប័ត្រព័ត៌មាន៖ សហគមន៍នេសាទ និងគម្រោងអភិវឌ្ឍនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា

ទិដ្ឋភាពរួម ៖ គម្រោងអភិវឌ្ឍនៅតែបន្តគំរាមកំហែងដល់អត្ថិភាពរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរដែលពួកគេពឹងអាស្រ័យកំពុងរងការទន្ទ្រានយក និងបំផ្លិចបំផ្លាញដោយមហិច្ឆិតាចង់បង្កើតជាតំបន់ទេសចរណ៍នៅតាមឆ្នេរសមុទ្រនៃប្រទេសកម្ពុជា។ សលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងឡើងបន្ថែមលើសលាកប័ត្រព័ត៌មានមុន អំពីសហគមន៍នេសាទដែលចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ក្នុងឆ្នាំ២០២១ និងផ្តោតទៅលើគម្រោងអភិវឌ្ឍដែលគំរាមកំហែងដល់សហគមន៍នេសាទតំបន់ឆ្នេរនៃខេត្តកំពត និងកែប។ សលាកប័ត្រព័ត៌មាននេះផ្តោតទៅលើគម្រោងដែលពាក់ព័ន្ធនឹងក្រុមហ៊ុនអុមនីកំពត ឌីវេឡុបមិន ខូអិលធីឌី (“ក្រុមហ៊ុនអុមនី”) ហើយប្រសិនបើគម្រោងអភិវឌ្ឍន៍នេះបន្តទៅមុខទៀត នឹងប៉ះពាល់ទៅដល់សហគមន៍នេសាទមួយចំនួននៅក្នុងខេត្តទាំងពីរ។ សលាកប័ត្រព័ត៌មាននេះបានធ្វើសេចក្តីសន្និដ្ឋានជាមួយនឹងអនុសាសន៍ជាក់លាក់ជូនដល់រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) និងធុរកិច្ចដើម្បីឱ្យការគោរពសិទ្ធិនេសាទ និងសិទ្ធិដីធ្លី និងសេរីភាពមូលដ្ឋាននៅតំបន់ឆ្នេរនៃប្រទេសកម្ពុជាកាន់តែប្រសើរឡើង។

១. សេចក្តីផ្តើម

សហគមន៍នេសាទបង្កើតឡើងជាផ្លូវការដោយព្រះរាជក្រឹត្យឆ្នាំ២០០៥ ដោយផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋកម្ពុជាក្នុងការរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមតំបន់ដែលគេរស់នៅ[1] ធ្វើឱ្យមានភាពប្រសើរឡើងក្នុងការគ្រប់គ្រងជលផលថ្នាក់មូលដ្ឋាន។ សហគមន៍នេសាទគឺជាម៉ាស៊ីនសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលបង្កើតជារចនាសម្ព័ន្ធជីវិតប្រចាំថ្ងៃនៃប្រជាពលរដ្ឋរាប់ម៉ឺននាក់ តាមរយៈការផ្គត់ផ្គង់ម្ហូបអាហារទៅដល់គ្រួសារនានានៅទូទាំងប្រទេសកម្ពុជា។ សហគមន៍នេសាទបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ក៏ដូចជាផ្តល់នូវសន្តិសុខស្បៀងយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងស្រុក។ ប្រជាពលរដ្ឋកម្ពុជា ស្ថិតនៅក្នុងចំណោមប្រជាពលរដ្ឋនៃបណ្តាប្រទេសដែលបរិភោគត្រីច្រើនបំផុតក្នុងពិភពលោកជាមួយនឹងអត្រាប៉ាន់ប្រមាណ ៣៧,៥ ទៅ ៦៧ គីឡូក្រាមនៃត្រីស្រស់សម្រាប់ប្រជាពលរដ្ឋម្នាក់ជារៀងរាល់ឆ្នាំ ហើយ៧៥ភាគរយនៃប្រជាពលរដ្ឋកម្ពុជាគឺ

[1] មាត្រា១ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ឆ្នាំ២០០៥។

ទទួលបានប្រូតេអ៊ីនដែលមាននៅក្នុងសាច់ត្រី។[2] ដោយសារហេតុផលនេះហើយ ទើបសហគមន៍នេសាទដើរតួយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជា។

ការចិញ្ចឹមជីវិតដែលពឹងអាស្រ័យលើមច្ឆជាតិ ធ្វើឱ្យសហគមន៍នេសាទយល់អំពីសារៈសំខាន់នៃសិទ្ធិមនុស្សមានដូចជាសិទ្ធិលំនៅឋាន ដែលបានក្លាយជាសិទ្ធិចាំបាច់បំផុតតម្រូវឱ្យមានការការពារក្នុងបរិបទនៃជំងឺកូវីដ១៩ ដែលកំពុងបន្តកើតមាន សិទ្ធិមានចំណីអាហារ សិទ្ធិទទួលបានការថែទាំសុខភាព និងសិទ្ធិទទួលបានការអប់រំសម្រាប់កូនៗរបស់ពួកគេ។ ប៉ុន្តែ ការរស់រានរបស់សហគមន៍នេសាទត្រូវរងការគំរាមកំហែងខ្លាំងឡើងដោយសារមានការកើនឡើងនៃចំនួនគម្រោងអភិវឌ្ឍនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសនៅសមុទ្រ និងតំបន់ឆ្នេរដែលជាគោលដៅទេសចរណ៍ដែលមានភាពទាក់ទាញខ្លាំងពីក្រុមអ្នកវិនិយោគ។ ដោយការទន្ទ្រានយកដែននេសាទដែលសហគមន៍កំពុងប្រកបមុខរបរនេសាទចិញ្ចឹមជីវិត គម្រោងអភិវឌ្ឍទាំងឡាយបានរារាំងសហគមន៍ពីការនេសាទ និងបានបំផ្លាញបរិស្ថានដែលបង្កការគំរាមកំហែងធ្ងន់ធ្ងរទៅដល់ការចិញ្ចឹមជីវិតរបស់សហគមន៍ និងប៉ះពាល់ដល់សន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា។

២. បញ្ហាចម្បង ៖ ការគំរាមកំហែងពីគម្រោងអភិវឌ្ឍដល់សហគមន៍នេសាទនៅក្នុងខេត្តកំពត និងខេត្តកែប

នៅខែមីនា ឆ្នាំ២០២១ អភិបាលខេត្តកំពតបានបង្ហាញពីសោមនស្សចំពោះការវិនិយោគដែលនៅបន្តមាននៅខេត្តកំពត ទោះបីជាមានការឆ្លងរាលដាលនៃជំងឺកូវីដ១៩ក្តី ហើយបានថ្លែងថា ទោះជាគម្រោងតូចឬធំក៏ជាសញ្ញាវិជ្ជមានសម្រាប់ប្រជាពលរដ្ឋ និងផ្តល់នូវកំណើនសេដ្ឋកិច្ចនៅក្នុងខេត្ត និងសម្រាប់ប្រទេសជាតិទាំងមូល។[3] លើសពីនេះ ការបើកសម្ពោធក្រុងបូកគោដែលជាទីក្រុងទីពីរនៅក្នុងខេត្តកំពតកាលពីខែសីហា ឆ្នាំ២០២១ ដើម្បីលើកកម្ពស់វិបុលភាពសេដ្ឋកិច្ច-សង្គម និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនឹងផ្តល់ក្តីសង្ឃឹមយ៉ាងខ្លាំងតាមរយៈគម្រោងវិនិយោគខ្នាតធំនៅក្នុងខេត្តនេះ។[4] គោលដៅពង្រីកលើវិស័យទេសចរណ៍ និងជំរុញកំណើកំណើនសេដ្ឋកិច្ចក្នុងខេត្តពិតជាធ្វើឱ្យមានការអនុ័តលើសំណើគម្រោងអភិវឌ្ឍនានាបន្ថែមលើក្រុងបូកគោ ឆ្ពោះយ៉ាងគម្រោង[5] ហ្ស្រេន រីវ៉ារ៉ា ម៉ារីណា កំពង់ផែទេសចរណ៍អន្តរជាតិកំពត[6] ការអភិវឌ្ឍធ្នើរនៅក្នុងខេត្តកែប[7] ការសាងសង់មណ្ឌលកស្តុការ និងកំពង់ផែពហុបំណង[8] និងការសាងសង់កំពង់ផែសមុទ្រនិងទីក្រុងរណប ឬកោះ

[2] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជា ស្តីពី ជលផល (គេហៈទំព័ររបស់រដ្ឋបាលជលផលនៃព្រះរាជាណាចក្រកម្ពុជា ដែលអាចចូលមើលបានថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២២)។

[3] ជង សុថា "ម្រេចកិនផ្តល់ក្តីសង្ឃឹមដល់ខេត្តកំពត" (ខ្មែរប៉ុស្ត៍អេស៊ា ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១)។

[4] រី សុចាន់ "ខេត្តកំពតបើកសម្ពោធក្រុងបូកគោ" (ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១)។

[5] គី កុសល "រមណីយដ្ឋានតម្លៃ២៣កោដិ៍ដុល្លារថ្មីក្នុងខេត្តកំពត" (ខ្មែរថ្មីមស៍ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧) "ក្រែលឡាសៈ ការយល់ព្រមលើសំណើគម្រោងអភិវឌ្ឍតម្លៃ ២៣.២ កោដិ៍ដុល្លារនៅកម្ពុជា" (ប៊ីលដ៏ប៊ីក អ៊ិនវេសម៉ិន គ្រុប ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១)។

[6] នៅ ស៊ីវ៉ុត្ថា "កំពង់ផែទេសចរណ៍ខេត្តកំពតសាងសង់បាន៩០ភាគរយ" (ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៩ ខែមករា ឆ្នាំ២០២២)។

[7] ប៊ុត រ. គង្គា "ធ្នើរកែបទទួលបានការកែប្រែមុខមាត់ថ្មី" (ខ្មែរថ្មីមស៍ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១)

[8] ហ៊ីន ពិសី "គម្រោងថ្មីតម្លៃ ១.៩ កោដិ៍ដុល្លារទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា" (ភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២)។

សិប្បនិម្មិត និងទីលានវាយកូនហ្គោល ក៏ដូចជារមណីយដ្ឋាន (សូមមើលផ្នែកទី៤) ដែលនេះគ្រាន់តែបង្ហាញឈ្មោះគម្រោងមួយចំនួនតែប៉ុណ្ណោះ។

ខណៈតម្រូវការផលប្រយោជន៍សេដ្ឋកិច្ចមិនអាចប្រកែកបាន គម្រោងខ្លះក្នុងចំណោមគម្រោងទាំងនោះមានទីតាំងនៅតាមឆ្នេរនៃខេត្តកំពត និងកែប បានជាន់លើដីសហគមន៍នេសាទក្នុងតំបន់។ បញ្ហាទាំងនេះរាប់បញ្ចូលទាំងសហគមន៍នេសាទជាច្រើន ទីតាំងនេសាទ និងសិទ្ធិ និងធនធានធម្មជាតិរួមទាំងជីវៈចម្រុះដែលសហគមន៍អាស្រ័យផលដើម្បីចិញ្ចឹមជីវិត និងការការពារពីគ្រោះធម្មជាតិកំពុងទទួលរងការគំរាមកំហែង។ លើសពីនេះ សិទ្ធិដែលផ្តល់ឱ្យសហគមន៍នេសាទក្នុងគោលបំណងធានាសុវត្ថិភាពតាមរយៈការចុះបញ្ជីជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែមិនបានផ្តល់ឱ្យសហគមន៍នូវភាពជាម្ចាស់ទៅលើដីដែលកំពុងកាន់កាប់នោះ នឹងអាចត្រូវបានរដ្ឋដកហូតមកវិញពេលណាក៏បាន។ អសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍នេសាទរស់នៅកាន់តែមានសភាពធ្ងន់ធ្ងរឡើង ដោយសហគមន៍នេសាទភ័យខ្លាចថានឹងត្រូវបានបណ្តេញចេញដោយពុំមានការជូនដំណឹងជាមុន ដោយសារតែអត្ថប្រយោជន៍នៃគម្រោងអភិវឌ្ឍផ្តល់កម្រៃច្រើនទៅរដ្ឋាភិបាលក្នុងការជំរុញវិស័យទេសចរណ៍នៅតំបន់ឆ្នេរ។

ការផ្តួចផ្តើមគំនិតរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់គម្រោងអភិវឌ្ឍដែលបង្កផលប៉ះពាល់អវិជ្ជមាន

បន្ថែមពីលើការបង្កើតសហគមន៍នេសាទដើម្បីការពារផលផល និងគ្រប់គ្រងធនធានផលផលនៅក្នុងប្រទេស និងកាតព្វកិច្ចផ្លូវច្បាប់សម្រាប់គម្រោងអភិវឌ្ឍក្នុងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (“ការវាយតម្លៃ”)[9] រដ្ឋាភិបាលបានបង្កើតស្ថាប័នជំនាញដើម្បីគ្រប់គ្រងនិងការពារតំបន់ឆ្នេរនៅក្នុងប្រទេស៖

➔ **គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា (“គណៈកម្មាធិការ”)**៖ គណៈកម្មាធិការ[10] បង្កើតឡើងដោយព្រះរាជក្រឹត្យឆ្នាំ២០១២ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរដ្ឋាភិបាល។ គណៈកម្មាធិការនេះ មានសមាសភាពពីមន្ត្រីរដ្ឋាភិបាលមកពីក្រសួងនានា រួមមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថានជាអនុប្រធាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាអនុប្រធានអចិន្ត្រៃយ៍ ហើយមាននាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស។

បេសកកម្មសំខាន់ៗក្នុងចំណោមបេសកកម្មដទៃទៀតរបស់ គណៈកម្មាធិការ មានដូចជា ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ គម្រោងមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃគម្រោងអភិវឌ្ឍ និងការអនុវត្តគម្រោងទាំងនេះនៅតំបន់ឆ្នេរសមុទ្រតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

[9] សូមមើលសលាកប័ត្រព័ត៌មានចេញផ្សាយដោយ ម.ស.ម.ក៖ “សហគមន៍នេសាទ និងគម្រោងអភិវឌ្ឍនៅតំបន់ឆ្នេរ” (ម.ស.ម.ក ខែកុម្ភៈ ឆ្នាំ២០២១) (សលាកប័ត្រព័ត៌មានលេខ១របស់ ម.ស.ម.ក)។

[10] ព្រះរាជក្រឹត្យ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

- ពិនិត្យ បង្ការ និងចាត់វិធានចាំបាច់ដើម្បីទប់ស្កាត់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- បញ្ជូនការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឱ្យយល់អំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ។

គណៈកម្មាធិការ ក៏អាចស្នើសុំកម្លាំងអន្តរាគមន៍ផងដែរដើម្បីអនុវត្តបេសកកម្មក្នុងករណីចាំបាច់។[11] គណៈកម្មាធិការ ក៏មានសាខានៅតាមខេត្តផងដែរ ប៉ុន្តែមិនមានព័ត៌មានអំពីគណៈកម្មាធិការថ្នាក់ខេត្តនេះដែលអាចរកឡើយ។

ទោះបីជាមានការផ្តួចផ្តើមគំនិតពីរដ្ឋាភិបាលក្តី សហគមន៍នេសាទនៅតែមិនទទួលបានការការពាររឹងមាំឡើយ (សូមមើលផ្នែកទី៣) ហើយអត្ថិភាពរបស់សហគមន៍នេសាទកំពុងប្រឈមដោយគម្រោងអភិវឌ្ឍ ដូចមាននៅក្នុងករណីសិក្សាពីសហគមន៍នេសាទទាំង៥ រួមមាន សហគមន៍កំពង់សាមគ្គី សហគមន៍ត្រពាំងសង្កែ នៅខេត្តកំពត សហគមន៍ភូមិថ្មី សហគមន៍កំពង់ត្រឡាច និងសហគមន៍អូរក្រសារ នៅខេត្តកែបដែលសហគមន៍ទាំង៥នេះកំពុងរងការគំរាមកំហែងពីគម្រោង អុមនី (សូមមើលផ្នែកទី៤)។

៣. ក្របខណ្ឌច្បាប់ស្តីពីសហគមន៍នេសាទ ដីធ្លី និងសិទ្ធិបរិស្ថាន

ការបំផ្ទិចបំផ្លាញ និងការទន្ទ្រានយកដែននេសាទសហគមន៍ដែលសហគមន៍ពឹងអាស្រ័យដោយគ្មានការយល់ព្រម និងការពិគ្រោះយោបល់ គឺជាការរំលោភបំពានសិទ្ធិមនុស្សជាអន្តរជាតិដែលមានចែងនៅក្នុងសន្ធិសញ្ញាផ្សេងភ្ជាប់កាតព្វកិច្ចមួយចំនួនដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ នៅក្រោមសន្ធិសញ្ញាអន្តរជាតិទាំងនេះ សហគមន៍នេសាទមានសិទ្ធិនិងត្រូវទទួលបានការការពារជាងពេលណាៗទាំងអស់ដែលធ្លាប់មានពីមុនមក ដូចជាសិទ្ធិមានលំនៅឋានសមរម្យនៅអំឡុងពេលមានការបន្តកើនឡើងនៃជំងឺកូវីដ១៩ជាដើម។ បន្ថែមពីលើនេះ លិខិតូបករណ៍អន្តរជាតិដែលមិនចងកាតព្វកិច្ចមួយចំនួនបានផ្តល់នូវគោលការណ៍ណែនាំទៅលើវិស័យដីធ្លីនិងដលផល ឬទៅលើកាតព្វកិច្ចរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស។ ជាចុងក្រោយ ក្របខណ្ឌច្បាប់របស់កម្ពុជាមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តមួយចំនួនស្តីពីសហគមន៍នេសាទ និងសិទ្ធិដីធ្លីដែលត្រូវការពារ ដូចដែលមានបង្ហាញនៅក្នុងតារាងខាងក្រោម ៖

[11] ប្រភពដូចខាងលើ មាត្រា៥ និង៧។

ច្បាប់អន្តរជាតិ	ច្បាប់អន្តរជាតិដែលមិនចងកាតព្វកិច្ច	ច្បាប់ជាតិ
• **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិយោបាយ ៖** - មាត្រា ១៩៖ សិទ្ធិទទួលបានព័ត៌មានជាការរួមបញ្ចូលសេរីភាពក្នុងការបញ្ចេញមតិ។ • **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ៖** - មាត្រា ៦៖ សិទ្ធិមានការងារធ្វើ - មាត្រា ១១៖ សិទ្ធិមានជីវភាពសមរម្យ សិទ្ធិមានចំណីអាហារ សិទ្ធិមានលំនៅឋាន - មាត្រា ១៥៖ សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌។	• **គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ (គោលការណ៍ណែនាំ)៖** គូសបញ្ជាក់ពី កាតព្វកិច្ចរបស់ធុរកិច្ច និងក្រុមហ៊ុនឯកជនក្នុងការគោរពសិទ្ធិមនុស្ស និងអនុវត្តគោលការណ៍ពិនិត្យដ៏ត្រឹមត្រូវ ធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការពិគ្រោះយោបល់ជាសាធារណៈ។ • **គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងថ្នាក់ជាតិ៖** ទទួលស្គាល់តួនាទីដ៏ចម្បងរបស់ជលផលនៅក្នុងការធ្វើឱ្យមានសិទ្ធិមនុស្ស និងផ្តល់ឱ្យក្នុងចំណោមនោះនូវអ្នកពាក់ព័ន្ធដែលអាស្រ័យផលជលផលក្នុងដំណើរការចូលរួមនៃអភិបាលកិច្ចសុវត្ថិភាពដីធ្លី និងក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ • **គោលការណ៍ស្ម័គ្រចិត្តសម្រាប់ការធានាវិស័យជលផលខ្នាតតូចប្រកបដោយចីរភាពក្នុងបរិបទសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ៖** គូសបញ្ជាក់ពីសារៈសំខាន់របស់រដ្ឋក្នុងការគ្រប់គ្រងសកម្មភាពនានារបស់តួអង្គមិនមែនរដ្ឋដែលបង្កផលប៉ះពាល់វិស័យជលផលខ្នាតតូច ដើម្បីធានាថាពួកគេបានអនុវត្តដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។	• **អនុក្រឹត្យឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ៖** ចែងអំពីការគ្រប់គ្រងនិងនីតិវិធីក្នុងការបង្កើតសហគមន៍នេសាទនៅប្រទេសកម្ពុជា។ • **ច្បាប់ស្តីពីជលផលឆ្នាំ ២០០៦៖** ធានានូវសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវធនធានជលផលសម្រាប់សហគមន៍នេសាទ។ • **ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨៖** ចែងអំពីក្របខណ្ឌនៃការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ការពារដែលមានរួមបញ្ចូលទាំងជលផលនៅក្នុងនោះផង។

ខណៈកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានបញ្ចូល និងអាចអនុវត្តដោយផ្ទាល់តាមរយៈមាត្រា៣១នៃរដ្ឋធម្មនុញ្ញប្រទេស

កម្ពុជានោះ ជាការគួរឱ្យសោកស្តាយ លិខិតតូបករណ៍អន្តរជាតិទាំងនេះមិនចងកាតព្វកិច្ច និងគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ និងគោលការណ៍ដទៃទៀតគឺនៅឆ្ងាយពីការដាក់ឱ្យអនុវត្តដោយរដ្ឋាភិបាល និងធុរកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ ស្រដៀងគ្នានេះ ច្បាប់ជាតិនៃប្រទេសកម្ពុជាដែលគ្រប់គ្រងសហគមន៍នេសាទ និងសិទ្ធិដីធ្លី មិនត្រូវបានការពារឱ្យបានពេញលេញសម្រាប់សហគមន៍នេសាទនោះទេ[12] និងមិនបានដាក់ឱ្យអនុវត្តដោយត្រឹមត្រូវដោយអាជ្ញាធរកម្ពុជានោះឡើយ។[13] ជាងនេះទៀត ច្បាប់ក្នុងស្រុក ដូចជាច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត (“ច្បាប់កូវីដ”) ថ្មីៗនេះក៏ត្រូវបានរដ្ឋាភិបាលប្រើប្រាស់ផងដែរក្នុងការកំណត់មុខសញ្ញាសកម្មជនដីធ្លី និងបរិស្ថាន ឬប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារជម្លោះដីធ្លីដែលតវ៉ាក្នុងការការពារសិទ្ធិដីធ្លី ជាមួយនឹងអាជ្ញាធរ ឬក្រុមហ៊ុនឯកជន។[14]

៣. ករណីសិក្សា ៖ សហគមន៍កំពង់សាមគ្គី ត្រពាំងសង្កែ កំពង់ត្រឡាច ភូមិថ្មី និងអូរក្រសារ និងក្រុមហ៊ុនអុមនី កំពត ឌីវេឡុបម៉ិន ខូអិលធីឌី[15]

កំពង់សាមគ្គី និងត្រពាំងសង្កែ ជាសហគមន៍នេសាទនៅតំបន់ឆ្នេរមានទីតាំងស្ថិតនៅក្នុងឃុំកូនសត្វ និងត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ សហគមន៍កំពង់សាមគ្គីបង្កើតឡើងនៅឆ្នាំ២០០៦ ដែលមានផ្ទៃដីនេសាទទំហំ ៥៣៧ ហិកតា មានសមាជិក ៤០៣ នាក់ ហើយសហគមន៍ត្រពាំងសង្កែបង្កើតឡើងជាផ្លូវការនៅឆ្នាំ២០០៩ គ្របដណ្ដប់លើផ្ទៃដីនេសាទទំហំ៣៣៧ ហិកតា និងមានសមាជិក៧៥៨នាក់។ សហគមន៍នេសាទកំពង់ត្រឡាច ភូមិថ្មី និងអូរក្រសារ ស្ថិតនៅក្នុងក្រុងកែប ខេត្តកែប សហគមន៍ទាំងបីនេះបង្កើតឡើងក្នុងឆ្នាំ២០០៥ដូចគ្នា។ សហគមន៍កំពង់ត្រឡាចគ្របដណ្ដប់លើផ្ទៃដីនេសាទទំហំ៤២២ ហិកតា ហើយមានសមាជិក

[12] សម្រាប់ព័ត៌មានបន្ថែមអំពីក្របខណ្ឌច្បាប់ក្នុងស្រុក សូមមើលសលាកប័ត្រព័ត៌មានលេខ១ចេញផ្សាយដោយ ម.ស.ម.ក។

[13] ក្រសួងពាណិជ្ជកម្ម ជីអ៊ីអេហ្ស យូអិនឌីភី & ប៉េមសៀ “ផ្ទៃនៃមហាសមុទ្រ និងតំបន់ឆ្នេរ ២០១៨៖ កំណើនសេដ្ឋកិច្ចព័ណ៌ខៀវនៅកម្ពុជា” (ក្រសួងពាណិជ្ជកម្ម ខែធ្នូ ឆ្នាំ២០១៩) ៤.១០ ទំព័រ៤៦។

[14] ម.ស.ម.ក “សលាកប័ត្រព័ត៌មាន៖ ការបណ្ដេញចេញដោយបង្ខំនៅកម្ពុជាអំឡុងពេលកូវីដ១៩” (ម.ស.ម.ក ខែតុលា ឆ្នាំ២០២១)។

[15] ព័ត៌មាននៅក្នុងផ្នែកនេះបានមកពីកិច្ចសម្ភាសរបស់ ម.ស.ម.ក លុះណាមានការបញ្ជាក់ផ្សេងពីនេះ។ អាស្រ័យដោយមានការរាលដាលនៃជំងឺកូវីដ១៩ ម.ស.ម.ក មិនអាចធ្វើការសិក្សាស្រាវជ្រាវនៅខេត្តកំពត និងកែប ក្នុងឆ្នាំ២០២១ តាមផែនការដែលបានគ្រោងពីមុនទេ។ ដោយមិនអាចចុះសម្ភាសដោយផ្ទាល់បាន ម.ស.ម.ក បានធ្វើការសម្ភាសតាមអនឡាញជាមួយសហគមន៍ចំនួន៣ក្នុងចំណោមសហគមន៍ដែលរងផលប៉ះពាល់ទាំង៥ពីគម្រោងអុមនី ក្នុងនោះបានសម្ភាសសមាជិក៥នាក់មកពីសហគមន៍កំពង់សាមគ្គី ២នាក់មកពីសហគមន៍ត្រពាំងសង្កែ ៥នាក់មកពីសហគមន៍អូរក្រសារ និងជាមួយអាជ្ញាធរមូលដ្ឋាន២នាក់ អាជ្ញាធរខេត្ត២នាក់ អង្គការក្នុងស្រុក៣នាក់ ក្នុងខែកក្កដា និងសីហា ឆ្នាំ២០២១។ លើសពីនេះ ម.ស.ម.ក បានដាក់សំណើសុំសម្ភាសទៅអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ខេត្តមួយចំនួនទៀត ប៉ុន្តែពួកគេបានបដិសេធ។ ម.ស.ម.ក បានព្យាយាមទាក់ទងទៅក្រុមហ៊ុនអុមនីដើម្បីសុំសម្ភាសផងដែរតែមិនបានជោគជ័យ។ ស្រដៀងគ្នានេះ ម.ស.ម.ក បានទាក់ទងទៅក្រុមហ៊ុនទីប្រឹក្សាដែលធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យក្រុមហ៊ុនអុមនី បន្ទាប់ពីព្រមផ្ដល់បទសម្ភាសដល់ ម.ស.ម.ក ក្រោយមកក៏បានបញ្ឈប់រាល់ការឆ្លើយឆ្លងជាមួយបុគ្គលិករបស់ ម.ស.ម.ក។ ក្រៅពីកិច្ចសម្ភាសទាំងប៉ុន្មាននេះ ព័ត៌មានតទៅគឺបានមកពី “របាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម៖ ផលប៉ះពាល់ពីគម្រោងអភិវឌ្ឍទៅលើធនធានបរិស្ថានសមុទ្រក្នុងខេត្តកំពត និងកែប” ដែលចេញផ្សាយរួមគ្នាដោយ អង្គការអាក់សិនអេតកម្ពុជា អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែតុលា ឆ្នាំ២០២១។

១១៥នាក់ ភូមិថ្មីមានផ្ទៃដីនេសាទ១៩៨ហិកតា ហើយមានសមាជិក១១០នាក់ ហើយអូរក្រសារមានផ្ទៃដីនេសាទទំហំ៤៤៦ហិកតា និងមានសមាជិក២៣៦នាក់។[16]

ការនេសាទគឺជាមុខរបរស្នូលសម្រាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាំងនេះ មានន័យថាសមាជិកភាគច្រើនពឹងផ្អែកទៅលើការនេសាទដើម្បីចិញ្ចឹមជីវិត និងធ្វើឱ្យមានសន្តិសុខស្បៀងសម្រាប់ក្រុមគ្រួសារនិងសហគមន៍ពួកគេ។[17] តាមរយៈកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាកន្លងទៅនេះ សមាជិកនៃសហគមន៍ទាំងបីបានលើកឡើងថា ការនេសាទពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហគមន៍ព្រោះជាប្រភពដំបូងនៃប្រាក់ចំណូល។ ការនេសាទក៏ជួយសហគមន៍ជិតខាងដទៃទៀតដែលមានសមាជិកមកនេសាទនៅទីនេសាទនៃសហគមន៍ទាំងបីអាចផ្គត់ផ្គង់ម្ហូបអាហារ ជាពិសេសគឺសហគមន៍ងាយរងគ្រោះដែលនៅជិតខាង។ សមាជិកសហគមន៍ដែលបានតបសម្ភាសន៍ក៏បានលើកឡើងដែរថា ការនេសាទនេះក្រៅពីមានសារៈសំខាន់លើសពីប្រាក់ចំណូល ក៏ជាផ្នែកមួយនៃប្រពៃណីក្នុងគ្រួសារដែលបន្តពីមួយជំនាន់ទៅមួយជំនាន់។ សមាជិកសហគមន៍ភាគច្រើនរៀនពីរបៀបនេសាទ និងបានធ្វើជាអ្នកនេសាទតាំងពីនៅក្មេងវ័យម្លេះ។ ការបាត់បង់សហគមន៍នេសាទ មិនត្រឹមតែបណ្តាលឱ្យបាត់បង់មុខរបរដ៏សំខាន់ប៉ុណ្ណោះទេ តែគឺជាការគំរាមកំហែងដល់អនាគតកូនចៅបន្ថែមទៀត។ ស្ត្រីម្នាក់ដែលបានតបបទសម្ភាសបានលើកឡើងថា ការនេសាទពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ត្រីនិងកុមារដែលពឹងផ្អែកទាំងស្រុងទៅលើការនេសាទដើម្បីចិញ្ចឹមជីវិត និងបានបន្ថែមថា ការនេសាទនេះអាចទប់ស្កាត់ចំណាកស្រុករបស់ប្រជាសហគមន៍ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅក្រៅប្រទេស។ ស្ត្រីម្នាក់ទៀតក៏បាននិយាយថា នាងធ្លាប់ជួបប្រទះនឹងការបាត់បង់ជីធ្លីនៅក្នុងសហគមន៍នេសាទ បណ្តាលឱ្យសមាជិកសហគមន៍ជាបុរសៗយ៉ាងច្រើន បង្ខំចិត្តធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសប្រទេស ទុកឱ្យភរិយានៅផ្ទះទទួលបន្ទុកគ្រួសារនិងមើលថែទាំកូនៗតែឯង។ បុរសជាប្តីមួយចំនួនមិនបានវិលត្រឡប់មកផ្ទះវិញទេ ទុកឱ្យភរិយាក្លាយជាស្ត្រីមេម៉ាយខំប្រឹងទ្រាំតស៊ូចិញ្ចឹមកូនៗរស់បន្តទៀត។

ក្នុងឆ្នាំ២០១៨ គម្រោងអភិវឌ្ឍដ៏ធំមួយរបស់ក្រុមហ៊ុន អុមនី នៅក្នុងតំបន់បានគំរាមកំហែងដល់សហគមន៍នេសាទចំនួន៥។ គម្រោងរបស់ក្រុមហ៊ុន អុមនី គ្រោងនឹងអភិវឌ្ឍលើផ្ទៃដីប្រមាណ ៣.៩១០ ហិកតា នៅក្នុងស្រុកទឹកឈូ ខេត្តកំពត និងនៅក្នុងខេត្តកែប ប្រែក្លាយឱ្យទៅជាកោះសិប្បនិម្មិតមួយក្នុងវិស័យទេសចរណ៍ ដែលគម្រោងនេះបានត្រួតគ្នាលើផ្ទៃដីដែលគ្រប់គ្រងដោយសហគមន៍នេសាទ។ ប្រសិនបើគម្រោងអភិវឌ្ឍនេះនឹងដំណើរការដូចការគ្រោងទុកមែននោះ គម្រោងនេះនឹងបំផ្លិចបំផ្លាញសមាជិកសហគមន៍នេសាទទាំង៥ រាប់ពាន់នាក់ និងប៉ះពាល់ផ្ទៃដីសហគមន៍នេសាទចាប់ពី ៤៧ ភាគរយ ទៅ ៧៨ ភាគរយ។[18]

ការចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងក្រសួងពាណិជ្ជកម្មបានបង្ហាញថា ក្រុមហ៊ុន អុមនី បានចុះបញ្ជី

[16] [របាយការណ៍រួមគ្នា](#) ចេញផ្សាយដោយអង្គការអាក់សិនអេតកម្ពុជា អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែតុលា ឆ្នាំ២០២១ ទំព័រទី៣។

[17] ប្រភពដូចខាងលើ ទំព័រទី១៥-១៦ បទសម្ភាសជាមួយ ម.ស.ម.ក។

[18] ព័ត៌មានដែលបានដកស្រង់ពីបទបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃបឋមហេតុប៉ះពាល់បរិស្ថាននិងសង្គមនៃគម្រោងរបស់ក្រុមហ៊ុន អុមនី ដែលបានធ្វើឡើងដោយក្រុមហ៊ុន ត្រីអេធីវ ហ្ស្ត្រីន ឌីហ្សាញ ខូអែលធីឌី ដែលបានរកឃើញដោយ ម.ស.ម.ក។

ពាណិជ្ជកម្មកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ ដែលតំណាងដោយនាយក/នាយិការបស់ក្រុមហ៊ុនចំនួនពីរនាក់ គឺឈ្មោះ ឃឹម រ៉ានី ជាភរិយារបស់មន្ត្រីជាន់ខ្ពស់ម្នាក់របស់រាជរដ្ឋាភិបាល និងឈ្មោះ មាង ចាន់ធី។ ក្រុមហ៊ុននេះនៅមិនទាន់មានគេហទំព័រនិងព័ត៌មានអំពីប្រតិបត្តិការរបស់ខ្លួនដែលត្រូវបានរកឃើញនៅឡើយទេ។ ព័ត៌មានដែលប្រមូលបានដោយ ម.ស.ម.ក ហាក់ដូចជាបង្ហាញពីអត្ថិភាពនៃការទំនាក់ទំនងគ្នារវាងក្រុមហ៊ុន អុមនី និងក្រុមរបស់ក្រុមហ៊ុន ភែលឡាស ប្រ៊ីលលាន អ៊ិនវេសម៉ិន អេន ឌីវេឡុបម៉ិន ខូអែលធីឌី ដែលជាក្រុមហ៊ុនអភិវឌ្ឍគម្រោងដ៏ធំមួយឈ្មោះ ហ្ស្រេន រីវ៉ារ៉ា ម៉ារីណា នៅក្នុងខេត្តកំពត។ ក្រុមហ៊ុនទាំងពីរនេះធ្លាប់មានប្រវត្តិមាននាយក/នាយិកា តែមួយគឺឈ្មោះ ឃឹម រ៉ានី[19] ហើយគម្រោងរបស់ក្រុមហ៊ុន អុមនី គឺគ្រោងនឹងអភិវឌ្ឍនៅលើទីតាំងរបស់ក្រុមហ៊ុន ភែលឡាស។[20] ទោះជាយ៉ាងណា ម.ស.ម.ក មិនអាចស្វែងរកប្រភពផ្លូវការណាមួយដែលបញ្ជាក់ពីទំនាក់ទំនងរវាងក្រុមហ៊ុនទាំងពីរបានឡើយ។

យោងតាមព័ត៌មានដែលប្រមូលបាន ក្រុមហ៊ុន អុមនី មានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងរបស់ខ្លួនដែលបានធ្វើឡើងដោយក្រុមហ៊ុនទីប្រឹក្សាឈ្មោះ គ្រីអេធីវ ហ្ស្ត្រីន ឌីហ្សាញ ខូអែលធីឌី។[21] ម.ស.ម.ក មិនអាចស្វែងរករបាយការណ៍វាយតម្លៃពេញលេញ ឬព័ត៌មានលម្អិតអំពីរបកគំហើញនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពីក្រុមហ៊ុនទាំងពីរនោះបានឡើយ។ នៅក្នុងបទសម្ភាស សហគមន៍នេសាទបានរាយការណ៍ថា សហគមន៍ត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំមួយចំនួនក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលសម្របសម្រួលដោយអាជ្ញាធរខេត្ត និងតំណាងរបស់ក្រុមហ៊ុន អុមនី។ សហគមន៍កំពង់សាមគ្គីបាននិយាយថា ប្រធានរបស់ពួកគេត្រូវបានអញ្ជើញចូលរួមកិច្ចប្រជុំចំនួន៤ ផ្សេងគ្នា ៖ កិច្ចប្រជុំទី១ ធ្វើឡើងក្នុងខែធ្នូ ឆ្នាំ២០១៨ និងកិច្ចប្រជុំចំនួន៣ ទៀត ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៩។ សហគមន៍ត្រពាំងសង្កែ និងសហគមន៍អូរក្រសារបានរាយការណ៍ថា សហគមន៍ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំតែម្តងគត់ក្នុងឆ្នាំ២០១៩។ យោងតាមសហគមន៍នេសាទដែលបានចូលរួមក្នុងកិច្ចប្រជុំទាំងនោះ តំណាងក្រុមហ៊ុន អុមនី បានធ្វើបទបង្ហញអំពីគម្រោងរបស់ក្រុមហ៊ុន និងរបកគំហើញនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ពួកគេ និងអំពីឱកាសការងារដែលគម្រោងនឹងផ្តល់ឱ្យសហគមន៍ទាំងនោះ។ ទោះយ៉ាងនេះក្តី តំណាងក្រុមហ៊ុនមិនដែលសួរយោបល់សហគមន៍អំពីគម្រោងរបស់ក្រុមហ៊ុនឡើយ។ តំណាងសហគមន៍កំពង់សាមគ្គីបានបញ្ជាក់ថា ពួកគាត់បានប្រាប់ទៅអាជ្ញាធរ និងក្រុមហ៊ុន ក្នុងអំឡុងពេលប្រជុំថា ពួកគាត់មិនយល់ស្របចំពោះគម្រោងរបស់ក្រុមហ៊ុននោះទេ និងសំណូមពរឱ្យក្រុមហ៊ុនទៅអភិវឌ្ឍនៅទីតាំងផ្សេងទៀត។ តំណាងសហគមន៍ត្រពាំងសង្កែបានថ្លែងនូវគំនិតស្រដៀងគ្នានេះ និងបានលើកឡើងអំពីការព្រួយបារម្ភដល់ផលប៉ះពាល់របស់គម្រោងចំពោះសហគមន៍

[19] ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ភែលឡាស ប្រ៊ីលលាន អ៊ិនវេសម៉ិន អេន ឌីវេឡុបម៉ិន ខូអែលធីឌី ក្នុងគេហទំព័រក្រសួងពាណិជ្ជកម្ម (ដែលបានរកឃើញកាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២) និងការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន អុមនី កំពត ឌីវេឡុបម៉ិន ខូអែលធីឌី ក្នុងគេហទំព័រក្រសួងពាណិជ្ជកម្ម (ដែលបានរកឃើញកាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២)។

[20] ព័ត៌មានដែលបានដកស្រង់ពីបទបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃបឋមហេតុប៉ះពាល់បរិស្ថាននិងសង្គមនៃគម្រោងរបស់ក្រុមហ៊ុន អុមនី ដែលបានធ្វើឡើងដោយក្រុមហ៊ុន គ្រីអេធីវ ហ្ស្ត្រីន ឌីហ្សាញ ខូអែលធីឌី ដែលបានរកឃើញដោយ ម.ស.ម.ក។

[21] យោងតាមការចុះបញ្ជីនៅក្រសួងពាណិជ្ជក្រុមហ៊ុននេះបានចុះបញ្ជីពាណិជ្ជកម្មកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧។ ក្នុងគេហទំព័រក្រសួងពាណិជ្ជកម្ម (ដែលបានរកឃើញកាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២)។

នេសាទរបស់ខ្លួន។ អ្នកទាំងអស់គ្នាបានអះអាងថា ក្រុមហ៊ុនបានច្រានចោលការបារម្ភទាំងនោះ។ ទោះយ៉ាងណាក៏ដោយ យោងតាមតំណាងសហគមន៍ត្រពាំងសង្កែថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលបានធ្វើឡើងដោយក្រុមហ៊ុន អុមនី នោះ ត្រូវបានបដិសេធក្នុងឆ្នាំ២០១៩ បន្ទាប់ពីមន្ត្រីជាន់ខ្ពស់ម្នាក់មកពីក្រសួងបរិស្ថានដែលបានចូលរួមក្នុងកិច្ចប្រជុំមួយបានថ្លែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះត្រូវបានធ្វើឡើងមិនត្រឹមត្រូវ និងបានស្នើឱ្យមានការវាយតម្លៃមួយថ្មីទៀត។ ម.ស.ម.ក មិនអាចស្វែងរកការបញ្ជាក់បន្ថែមពីអាជ្ញាធរពាក់ព័ន្ធដទៃទៀតអំពីព័ត៌មាននេះទេ។

ពុំមានអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តណាម្នាក់ដែល ម.ស.ម.ក សម្ភាស អាចផ្តល់ព័ត៌មានអំពីគម្រោងរបស់ក្រុមហ៊ុន អុមនី នេះឡើយ។ អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋានដែលផ្តល់បទសម្ភាសបានរាយការណ៍ថា ធ្លាប់បានឮអំពីគម្រោងរបស់ក្រុមហ៊ុននេះដែរ។ តំណាងអង្គការមិនមែនរដ្ឋភិបាលម្នាក់បាននិយាយថា គម្រោងរបស់ក្រុមហ៊ុននេះបានចាប់ផ្តើមក្នុងឆ្នាំ២០១៨ និងបានបញ្ជាក់ថាក្រុមហ៊ុននេះបានបើកការប្រជុំមួយចំនួនក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលពេលនោះ តំណាងក្រុមហ៊ុនបានធ្វើបទបង្ហាញ អំពីរបកគំហើញនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ក្រុមហ៊ុន និងបានសន្យាពីការផ្តល់ការងារដល់សហគមន៍ដែលពាក់ព័ន្ធ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលម្នាក់ទៀត ដែលបានចូលរួមកិច្ចប្រជុំនោះដែរបញ្ជាក់ថា មានតែរបកគំហើញវិជ្ជមាននៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ប៉ុណ្ណោះដែលបានលើកបង្ហាញទៅអ្នកពាក់ព័ន្ធ។ ទោះជាយ៉ាងណា ភាគច្រើននៃសហគមន៍ដែលរងផលប៉ះពាល់មិនត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះទេ និងបាននិយាយថាពួកគាត់មិនទាំងបានដឹងថាក្រុមហ៊ុនបានបើកកិច្ចប្រជុំទាំងនោះផង។ នៅពេលសួរអំពីការសន្យារបស់ក្រុមហ៊ុនថានឹងផ្តល់ការងារឱ្យសហគមន៍នេសាទ សមាជិកសហគមន៍ដែលតបបទសម្ភាសបានឆ្លើយថា តាមបទពិសោធកន្លងមក ការងារដែលផ្តល់ឱ្យដោយក្រុមហ៊ុន និងការសន្យាអំពីប្រាក់ខែខ្ពស់នោះមិនអាចទុកចិត្តបានទេ ពីព្រោះថាភាគច្រើនក្រុមហ៊ុនសន្យាដូច្នេះគឺគ្រាន់តែចង់បានការឯកភាពពីសហគមន៍នេសាទដើម្បីបានដំណើរការគម្រោងរបស់គេតែប៉ុណ្ណោះ ប៉ុន្តែក្រុមហ៊ុនកម្រនឹងធ្វើតាមការសន្យារបស់ខ្លួនណាស់។ ទោះបីជានឹងមានការផ្តល់ឱកាសការងារពិតមែនក៏ដោយ តែសមាជិកសហគមន៍ភាគច្រើនទទួលបានការអប់រំទាប ដូចនេះមិនអាចទទួលបានប្រាក់ខែល្អនោះឡើយ និងពឹងផ្អែកតែទៅលើការសម្រេចចិត្តរបស់និយោជកធានាទៅលើជីវភាពរស់នៅរបស់ពួកគាត់ រួមទាំងប្រឈមនឹងការបាត់បង់ការងារគ្រប់ពេលវេលា។ លើសពីនោះទៀត ក្រុមហ៊ុននឹងមិនជួលសមាជិកសហគមន៍ដែលមានវ័យចំណាស់នោះទេ។ ពួកគាត់បានគូសបញ្ជាក់ថា ទឹកដីដែលពួកគាត់កំពុងរស់នៅនិងការនេសាទ អនុញ្ញាតឱ្យសហគមន៍នេសាទមានភាពឯករាជ្យ និងម្ចាស់ការដោយខ្លួនឯងសម្រាប់មនុស្សជំនាន់ក្រោយ ហើយសមាជិសហគមន៍អាចរកចំណូលបានជាទៀងទាត់ និងស្មេរភាព រួមទាំងការចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដោយមិនគិតពីអាយុ និងកម្រិតនៃការអប់រំឡើយ។ ពួកគាត់បានបញ្ជាក់ផងដែរថា នៅក្នុងសហគមន៍នេសាទរបស់ពួកគាត់គឺអាចមានមធ្យោបាយច្រើនដើម្បីធានាជីវភាពរស់នៅ និងជាមធ្យោបាយដ៏ប្រសើរបំផុតក្នុងការការពារបរិស្ថាន និងធនធានធម្មជាតិ។ សហគមន៍នេសាទ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់បទសម្ភាសទទួលស្គាល់ថា

គម្រោងអភិវឌ្ឍនានាអាចមានផលវិជ្ជមានសម្រាប់សេដ្ឋកិច្ចជាតិនិងថ្នាក់មូលដ្ឋាននិងអាចបង្កើតការងារសម្រាប់សហគមន៍នៅក្នុងតំបន់។

ព្រៃកោងកាងនៅសហគមន៍នេសាទត្រពាំងសង្កែក្នុងខេត្តកំពត

ទោះជាយ៉ាងណា ទាំងអស់គ្នាយល់ស្របថា ផលប៉ះពាល់អវិជ្ជមានរបស់គម្រោងទាំងអស់នោះ ជាពិសេសគឺការធ្វើឱ្យអន្តរាយបរិស្ថានដែលមិនអាចជួសជុលវិញបាន និងការបំផ្លិចបំផ្លាញធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ និងដីវ:ចម្រុះដែលនឹងកើតមានឡើងនោះ គឺខុសគ្នាឆ្ងាយពីផលប៉ះពាល់វិជ្ជមាន។ ការព្រួយបារម្ភអំពីផលប៉ះពាល់ដែលធ្វើឱ្យខូចប្រយោជន៍ជាច្រើនបណ្តាលមកពីគម្រោងអភិវឌ្ឍទាំងនោះ ទៅលើបរិស្ថាន និងការរស់នៅរបស់សហគមន៍មូលដ្ឋានដែលពឹងផ្អែកទៅលើធនធានធម្មជាតិ ត្រូវបានយល់ស្របដោយអាជ្ញាធរមួយចំនួនដែលផ្តល់បទសម្ភាសដោយបានថ្លែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដ៏ត្រឹមត្រូវ ត្រូវតែធ្វើឡើងមុនពេលអនុញ្ញាតឱ្យគម្រោងណាមួយអភិវឌ្ឍ ដោយអនុលោមទៅតាមការកំណត់របស់ច្បាប់ក្នុងស្រុក។

ចំណោទនៅជុំវិញគម្រោងអភិវឌ្ឍ គឺជាការព្រួយបារម្ភមួយផ្សេងទៀត។ កង្វះព័ត៌មានជាច្រើនជុំវិញគម្រោងអភិវឌ្ឍទាំងនោះ រួមទាំងកង្វះខាតការយល់ដឹងរបស់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍ ដោយពួកគាត់បាននិយាយថា ធ្លាប់បានឮអំពីគម្រោងទាំងនោះដែលនឹងអាចប៉ះពាល់សហគមន៍របស់ពួកគាត់ តែពីអង្គការមិនមែនរដ្ឋាភិបាល ឬនៅពេលដែលក្រុមហ៊ុនទាំងនោះបានចុះមកស្វែងរកការឯកភាពរបស់ពួកគាត់ ឱ្យគាំទ្រគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន។ សហគមន៍ ក៏ពឹងផ្អែកតែទៅលើព័ត៌មានដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរខេត្តដែលពួកគាត់ក៏នៅមិនទាន់បានទទួលព័ត៌មានគ្រប់គ្រាន់អំពីគម្រោងទាំងអស់នោះផងដែរ។ កង្វះតម្លាភាពនៃគម្រោងអភិវឌ្ឍត្រូវបានលើកឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានថា ជាការគួរឱ្យសោកស្តាយដែលពុំមានព័ត៌មានគ្រប់គ្រាន់សម្រាប់សាធារណជនអាចស្វែងរកបានអំពីគម្រោងអភិវឌ្ឍនានា។

មានការលើកឡើងដូចគ្នានេះផងដែរអំពីគណ:កម្មាធិការ។ ក្នុងខណ:ដែលអ្នកតបបទសម្ភាសមួយចំនួនបាននិយាយថាធ្លាប់បានឮអំពីអត្ថិភាពរបស់គណ:កម្មាធិការខាងលើ ឬដឹងអំពីសមាសភាពសមាជិកខ្លះ។ នៃគណ:កម្មាធិការនេះយ៉ាងណាក្តី ក៏ពុំមានអាជ្ញាធរដែលបានផ្តល់បទសម្ភាសណាម្នាក់ដឹងច្បាស់អំពីតួនាទី

និងសកម្មភាពរបស់គណៈកម្មាធិការនេះនៅក្នុងខេត្តកំពត និងខេត្តកែបដែរ ដែលអាចលើកជាសំណួរអំពីប្រសិទ្ធភាពរបស់ គណៈកម្មាធិការ និងភាពសកម្មក្នុងការគ្រប់គ្រង និងការពារតំបន់ឆ្នេរសមុទ្រ។ អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានមួយដែលហាក់ដូចជាដឹងច្បាស់អំពី គណៈកម្មាធិការ និងសាខាថ្នាក់ខេត្តរបស់គណៈកម្មាធិការនេះ បានសម្តែងអំពីការសោកស្តាយចំពោះកង្វះខាតសកម្មភាព ក៏ដូចជាកង្វះខាតនៃការអនុវត្តក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ដើម្បីការពារសហគមន៍នេសាទ និងតំបន់ឆ្នេរសមុទ្រ បើទោះជាអាជ្ញាធរខេត្តម្នាក់ដែលតបបទសម្ភាសចាត់ទុកថា ច្បាប់ដែលកំពុងត្រូវបានអនុវត្តនោះអាចការពារសហគមន៍នេសាទបាន។ ទោះយ៉ាងណា អាជ្ញាធរថ្នាក់មូលដ្ឋានម្នាក់បានលើកឡើងអំពីតម្រូវការចាំបាច់ក្នុងការផ្សព្វផ្សាយដោយអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរអំពីក្របខ័ណ្ឌច្បាប់ការពារសហគមន៍នេសាទ។

ក្រុមហ៊ុនខាងលើហាក់ស្ងាត់ស្ងៀមតាំងពីកិច្ចប្រជុំចុងក្រោយបានធ្វើឡើងក្នុងឆ្នាំ២០១៩។ ពុំមានអ្នកផ្តល់បទសម្ភាសណាម្នាក់រួមទាំងអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តដឹងច្បាស់ថាតើ ក្រុមហ៊ុននេះកំពុងបន្តប្រតិបត្តិការរបស់ខ្លួន និងដឹងអំពីស្ថានភាពពិតប្រាកដរបស់គម្រោងក្រុមហ៊ុន អុមនី ឡើយ។ សហគមន៍នេសាទកំពុងមានក្តីបារម្ភប្រសិនជាគម្រោងរបស់ក្រុមហ៊ុននឹងដំណើរការមែននោះ ពួកគេនឹងបាត់បង់អ្វីៗគ្រប់យ៉ាងពីទឹកដី និងធនធានធម្មជាតិដែលកំពុងពឹងអាស្រ័យក្នុងការនេសាទតាមលក្ខណៈប្រពៃណី និងអនាគតកូនចៅ។

៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គម្រោងអភិវឌ្ឍកំពុងបន្តគំរាមកំហែងសហគមន៍នេសាទយ៉ាងធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា និងប៉ះពាល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋខ្មែររាប់ពាន់នាក់។ ក្នុងខណៈដែលគម្រោងអភិវឌ្ឍនានាអាចទាញយកប្រយោជន៍ពីសេដ្ឋកិច្ចរបស់ប្រទេសជាតិ គឺមានសារៈសំខាន់ណាស់ដែលសហគមន៍នេសាទនឹងត្រូវទទួលបានការគិតគូរយ៉ាងត្រឹមត្រូវ ហើយត្រូវបានជូនដំណឹងប្រកបដោយអត្ថន័យ និងការចូលរួម។ គម្រោងអភិវឌ្ឍនានាដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិការនៅតាមតំបន់ឆ្នេរសមុទ្រដើម្បីកំណើនសេដ្ឋកិច្ចជាតិនោះ នឹងមិនអាចសម្រេចបានដោយការបំពានសិទ្ធិមនុស្សឡើយ។ ដូចនេះ ម.ស.ម.ក សូមផ្តល់នូវអនុសាសន៍ដូចបានលើកកាលពីលើកមុនជូនដល់រាជរដ្ឋាភិបាល និងធុរកិច្ចដែលកំពុងប្រតិបត្តិការនៅកម្ពុជាដូចខាងក្រោម ៖

អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា ៖

១. **ធ្វើកំណែទម្រង់ច្បាប់ឱ្យបានត្រឹមត្រូវ** ដើម្បីឱ្យច្បាប់ជាតិអនុលោមតាមបទដ្ឋានអនុវត្តល្អប្រសើរ ដូចមានចែងក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ដីធ្លី និងព្រៃឈើ ក្នុងបរិបទសុវត្ថិភាពស្បៀងថ្នាក់ជាតិ និងការលុបបំបាត់ភាពក្រីក្រ។ ទាំងនេះ គួររួមបញ្ចូលនូវដំណើរការក្រៅផ្លូវការក្នុងការទទួលស្គាល់ ការពារ និងសម្របសម្រួលសិទ្ធិស្របច្បាប់នៃសហគមន៍នេសាទចំពោះកន្លែងនេសាទ និងដីនៅជុំវិញនោះ។

២. **ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងតួអង្គសំខាន់ៗ** ឱ្យយល់ដឹងពី**សិទ្ធិកាន់កាប់ស្របច្បាប់របស់សហគមន៍នេសាទនៅតំបន់ឆ្នេរ** រួមមានការបង្កើតគោលការណ៍ណែនាំសម្រាប់អាជ្ញាធរមូលដ្ឋានឱ្យបញ្ជាក់ ឬចេញប័ណ្ណកម្មសិទ្ធិឱ្យសហគមន៍នេសាទនៅតំបន់ឆ្នេរ។

៣. **ដោះស្រាយដោយមានប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់** ហើយត្រូវធានាថារាល់ដំណោះស្រាយត្រូវឆ្លើយតបនឹងប្រសិទ្ធភាពតម្រូវតាមគោលការណ៍លេខ៣១នៃគោលការណ៍ណែនាំ។

៤. ត្រូវធានាឱ្យមានកិច្ច**ពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់** មុនចុះកិច្ចសន្យាសម្រាប់ការអភិវឌ្ឍ និងធានាឱ្យមានការជូនដំណឹងទៅដល់សហគមន៍ព្រមទាំងផ្តល់ការយល់ព្រមមុនប្រគល់សិទ្ធិកន្លែងនេសាទ។

៥. **តម្រូវឱ្យមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានច្បាស់លាស់ មុនអនុញ្ញាតឱ្យមានគម្រោងអភិវឌ្ឍ ឬហេដ្ឋារចនាសម្ព័ន្ធ ឬតំបន់សេដ្ឋកិច្ចពិសេស** ហើយត្រូវធានាឱ្យមានការចូលរួមពីសហគមន៍រងផលប៉ះពាល់ និងសាធារណជនក្នុងពេលវេលាសមស្របណាមួយ ហើយយន្តការនៃការអនុវត្តដែលបានប្រើប្រាស់នោះគឺស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមមានគោលការណ៍លេខ ១៨ នៃគោលការណ៍ណែនាំ។

៦. បង្កើត និងអនុម័ត **ផែនការសកម្មភាពជាតិស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្ស** ដោយការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ធ្វើការផ្សព្វផ្សាយ និងអនុវត្តនូវគោលការណ៍ណែនាំ។

អនុសាសន៍ចំពោះធុរកិច្ច ៖

៧. **អនុវត្តគោលការណ៍ពិនិត្យដ៏ត្រឹមត្រូវ** មុនចាប់ផ្តើមរាល់ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយអនុលោមទៅតាមគោលការណ៍លេខ ១៥ ១៧ និង ១៨ នៃគោលការណ៍ណែនាំ។

៨. **ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម** ឱ្យមានការចូលរួមពីសហគមន៍ដែលរងផលប៉ះពាល់ និងសាធារណជនឱ្យបានទាន់ពេលវេលា ហើយនិងដាក់ចេញនូវយន្តការត្រួតពិនិត្យការអនុវត្តដោយអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មានដូចជា គោលការណ៍លេខ ១៨ នៃគោលការណ៍ណែនាំ។

៩. ពិគ្រោះយោបល់ជាមួយ **សហគមន៍រងផលប៉ះពាល់ អ្នកពាក់ព័ន្ធសំខាន់ៗ និងអាជ្ញាធរ** ប្រកបដោយអត្ថន័យ ទាន់ពេលវេលា និងមានតម្លាភាព យកទៅគិតគូរ និងដោះស្រាយនូវកង្វល់របស់ពួកគេ។

១០.ដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះរាល់ការរំលោភបំពានសិទ្ធិមនុស្ស និងធានាថារាល់ដំណោះស្រាយឆ្លើយតបនឹងតម្រូវការប្រកបដោយប្រសិទ្ធភាពនៃគោលការណ៍ណែនាំលេខ ៣១ នៃគោលការណ៍ណែនាំ។

១១.បង្កើត**យន្តការបណ្តឹងសាទុក្ខកម្រិតប្រតិបត្តិប្រកបដោយប្រសិទ្ធភាព អាចដំណើរការ និងមានតម្លាភាព** ដើម្បីឱ្យអ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីសកម្មភាពសាជីវកម្មស្របតាមគោលការណ៍លេខ ២៩ នៃគោលការណ៍ណែនាំ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធានាសុវត្ថិភាពសិទ្ធិកាន់កាប់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិសម្រាប់សហគមន៍នេសាទងាយរងគ្រោះនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជានៃ ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) (0) ១២ ៩៤១ ២០៦ ឬអ៊ីមែល៖ vann.sophath@cchrcambodia.org។